ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ១១ អយក.សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយ របស់ក្រសួងអប់រំ យុវជន និងកីឡា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០២៣ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៧/៣៨៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលមាត្រា១ និងមាត្រា២នៃព្រះរាជក្រឹត្យលេខនស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- បានឃើញអនុក្រឹត្យលេខ ១៨៧ អនក្រ.បក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ

## **សម្រេច**

**ប្រការ១** ._

ត្រូវបានបង្កើតក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយនៅក្រសួងអប់រំ យុវជន និងកីឡា ដែលសរសេរជាអក្សរកាត់ថា "**ក.ក.ភ១.ផ១**"។

**ប្រការ២** ._

ក.ក.ភ១.ផ១. ក្រសួងអប់រំ យុវជន និងកីឡាមានសមាសភាពដូចតទៅៈ

| | | | |
|---|---|---|---|
| ១. ឯកឧត្ដម | **ពុត សាមិត្ត** | អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ | ប្រធាន |
| ២. ឯកឧត្ដម | **ឱម សិទ្ធី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ | អនុប្រធាន |
| ៣. លោកបណ្ឌិត | **សំអោ អង្គារតន៍** | អគ្គនាយករងនៃអគ្គនាយកដ្ឋាន គោលនយោបាយ និងផែនការ | អនុប្រធាន |
| ៤. លោក | **រ័ត្ន សារ៉ា** | ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | អនុប្រធាន |
| ៥. លោក | **នួន វណ្ណាសឿន** | អនុប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | អនុប្រធានអចិន្ត្រៃយ៍ |
| ៦. លោក | **សំ ចាន់ធិត** | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | សមាជិក |
| ៧. លោក | **ប៊ុត សុភាន់** | អនុប្រធាននាយកដ្ឋានមធ្យមសិក្សា | សមាជិក |
| ៨. លោក | **សុភ ណុប** | អនុប្រធាននា.គ្រប់គ្រងមជ្ឈមណ្ឌលយុវជន | សមាជិក |
| ៩. លោក | **ខែត សុផលរឹទ្ធិ** | ប្រធានការិ. នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១០. កញ្ញា | **ឃឹម ចរិយា** | អនុប្រធានទទួលបន្ទុករួមការិ.នា. តទវ | លេខាធិការ |

ក.ក.ភ១.ផ១.ក្រសួងអប់រំ យុវជន និងកីឡាអាចបន្ថែមសមាជិក សមាជិកាតាមការចាំបាច់។

**ប្រការ៣** ._

ក.ក.ភ១.ផ១. ក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការជូនឯកឧត្ដម **អ៊ឹម កុច** រដ្ឋលេខាធិការ តំណាងក្រសួងអប់រំ យុវជន និងកីឡាក្នុងសមាជិកគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ហើយ ក.ក.ភ១.ផ១.មានតួនាទីនិងភារកិច្ចដូចតទៅៈ

- សម្របសម្រួលនិងសហការជាមួយនឹងអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយនៃគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងឯកសារគតិយុត្តពាក់ព័ន្ធនានាក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ
- ចូលរួមសហការនិងផ្តល់យោបល់លើឯកសារគតិយុត្តនានាដែលអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយបានតាក់តែងរៀបចំក្នុងការងារជំរុញចលនាភូមិមួយផលិតផលមួយ
- ចូលរួមសហការអនុវត្តសកម្មភាពនានា ជាមួយនឹងអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយនៃគណៈកម្មការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- សម្របសម្រួលនិងសហការជាមួយនឹងអង្គភាព ឬនាយកដ្ឋានពាក់ព័ន្ធនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយគណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយថ្នាក់រាជធានី ខេត្ត និងមន្ទីរខ្សែបណ្តោយរបស់សាមីអង្គភាពនៅថ្នាក់រាជធានី ខេត្តក្នុងការងារជំរុញចលនាភូមិមួយផលិតផលមួយ
- សម្របសម្រួលនិងសហការជាមួយនឹងអង្គភាព ឬនាយកដ្ឋានពាក់ព័ន្ធនៅក្នុងក្រសួង ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងការងារជំរុញចលនាភូមិមួយផលិតផលមួយក្នុងដែនសមត្ថកិច្ចរបស់ក្រសួង
- រៀបចំផែនការការងារប្រចាំឆ្នាំរបស់ក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយ និងដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យនិងអនុម័ត
- ពិនិត្យតាមដាននិងវាយតម្លៃការងារជំរុញចលនាភូមិមួយផលិតផលមួយក្នុងដែនសមត្ថកិច្ចរបស់ក្រសួង
- ធ្វើរបាយការណ៍ប្រចាំត្រីមាស ឆមាស និងរបាយការណ៍ប្រចាំឆ្នាំរបស់ ក.ក.ភ១.ផ១. ជូនថ្នាក់ដឹកនាំ ក្រសួង និងគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ក្នុងការងារជំរុញចលនាភូមិមួយផលិតផលមួយ។

**ប្រការ៤**._

សមាជិក ក.ក.ភ១.ផ១. ក្រសួងអប់រំ យុវជន និងកីឡាត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវដឹកនាំការប្រជុំជំនួស។ ប្រធាន ក.ក.ភ១.ផ១. មានសិទ្ធិអញ្ជើញមន្ត្រីពាក់ព័ន្ធផ្សេងទៀតស្ថិតក្នុងទីស្តីការក្រសួងអប់រំ យុវជន និងកីឡា និងមន្ត្រីទទួលបន្ទុកជំនាញនៃអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ៥**._

ក.ក.ភ១.ផ១. ក្រសួងអប់រំ យុវជន និងកីឡាត្រូវធ្វើការប្រជុំយ៉ាងតិច ៣ (បី)ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ក.ក.ភ១.ផ១. អាចប្រជុំវិសាមញ្ញបាន តាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៦**._

ក.ក.ភ១.ផ១. ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងដើម្បីបំពេញការងារ។

**ប្រការ៧**._

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៣៨ ១១៣៦ ខែ៤៥ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ៥៧ ឆ្នាំ២០១៨

**កន្លែងទទួល**
- -អគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយ
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- -អង្គភាពក្រោមឱវាទទីស្ដីការក្រសួង
- -មន្ទីរ អ.យ.ក រាជធានី ខេត្តទាំង២៥
  "ដើម្បីសហការ"
- -ដូចប្រការ ២ "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ-ឯកសារ. តទវ

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**